ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៩០ ព.ណ.ប.ល.ប្រក

# ប្រកាស
# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** :

វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ហើយមានមុខងារ និងភារកិច្ចដូចតទៅ៖

- កសាងផែនការ និងរៀបចំកម្មវិធីសិក្សាលើគ្រប់មុខជំនាញពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងសេដ្ឋកិច្ច ដើម្បីធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ទាំងរយៈពេលខ្លី មធ្យម និងរយៈពេលវែង



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
ទូរស័ព្ទ / ទូរសារ៖ (៨៥៥)-២៣ ៨៦៦ ៤៦៩
Phone/Facsimile: (855)-23 866 469

- អនុវត្តការងារបណ្តុះបណ្តាល បំប៉នចំណេះដឹងដល់មន្ត្រីរាជការនៃស្ថាប័នអង្គភាពសាធារណៈ និង មន្ត្រី បុគ្គលិក មកពីវិស័យឯកជន ឬសិស្ស និស្សិតទូទៅ តាមកម្មវិធីសិក្សា និងតាមតម្រូវការចាំបាច់
- អនុវត្តកិច្ចសហប្រតិបត្តិការ សម្របសម្រួលក្នុងការបើកវគ្គបណ្តុះបណ្តាលនានា ក្រោមគម្រោងជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ឬពីអង្គការជាតិ និងអន្តរជាតិ
- បំពេញការងារជាអ្នកសម្របសម្រួលនៅគ្រប់វគ្គបណ្តុះបណ្តាល ទាំងអស់របស់ក្រសួងពាណិជ្ជកម្ម
- គ្រប់គ្រងបណ្ណាល័យរបស់ក្រសួងពាណិជ្ជកម្ម
- ផ្តល់ប្រឹក្សាលើការធ្វើអាជីវកម្ម និងការវិនិយោគ
- សហការធ្វើការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិ គោលការណ៍ និងនីតិវិធីពាក់ព័ន្ធ ជូនដល់មន្ត្រីក្រសួងពាណិជ្ជកម្ម និងសហគមន៍ខាងក្រៅ
- ធ្វើការសិក្សាស្រាវជ្រាវលើវិស័យពាក់ព័ន្ធ របស់ក្រសួងពាណិជ្ជកម្ម
- ស្វែងរកដៃគូ និងសហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការទទួល និងប្រើប្រាស់ជំនួយបច្ចេកទេស ទាក់ទងនឹងការបណ្តុះបណ្តាល និងការស្រាវជ្រាវ
- អភិវឌ្ឍន៍ប្រព័ន្ធកម្មវិធីសិក្សា និងឯកសារបណ្តុះបណ្តាលតាមប្រព័ន្ធអ៊ីនធឺណិត
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ២** :

វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ ដឹកនាំដោយប្រធានវិទ្យាស្ថាន មួយរូប និងអនុប្រធានវិទ្យាស្ថានមួយចំនួន ជាជំនួយការ។

**ប្រការ ៣** :

វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ មានការិយាល័យចំណុះចំនួន ០៤ គឺៈ

១- ការិយាល័យរដ្ឋបាល និងផែនការ

២- ការិយាល័យបណ្តុះបណ្តាល

៣- ការិយាល័យអភិវឌ្ឍន៍ភាពជាដៃគូ និងអាជីវកម្ម

៤- ការិយាល័យស្រាវជ្រាវ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៤** :

ការិយាល័យរដ្ឋបាល និងផែនការ មានភារកិច្ច ៖

- សម្របសម្រួលកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- រៀបចំគ្រប់គ្រងថវិកា និងលើកផែនការចំណូល ចំណាយ រួមទាំងថវិកា ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍
- សហការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការការងារ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការការងារ
- គ្រប់គ្រង ថែរក្សា និងធ្វើបច្ចុប្បន្នភាពសម្ភារ បរិក្ខារនានា
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់វិទ្យាស្ថាន
- គ្រប់គ្រង និងរក្សាទិន្នន័យក្នុងទម្រង់អេឡិចត្រូនិក និងរក្សាឯកសាររដ្ឋបាល ទាំងអស់របស់វិទ្យាស្ថាន
- ធ្វើការវិភាគ អំពីទំហំការងារ និងជំនាញការងារ គ្រប់គ្រងវត្តមាន និងបេសកកម្មរបស់មន្ត្រីនៃវិទ្យាស្ថាន
- សហការជ្រើសរើសសិក្ខាកាមឲ្យចូលរួមវគ្គបណ្តុះបណ្តាល
- បំពេញការងារជាចំណុចកណ្តាល ក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងការចុះឈ្មោះក្នុងវគ្គបណ្តុះបណ្តាលរបស់វិទ្យាស្ថាន និងស្រាវជ្រាវ ផ្តល់ព័ត៌មាន និងចម្លើយ ទាក់ទងនឹងសំណួរស្នូគស្មាញ ឲ្យដល់មន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម និងសហគមន៍ ខាងក្រៅ
- រៀបចំបូកសរុបរបាយការណ៍របស់វិទ្យាស្ថាន និងរៀបចំរបាយការណ៍វិភាគ អំពីភាពចន្លោះប្រហោងរបស់ការិយាល័យ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៥** :

ការិយាល័យបណ្តុះបណ្តាល មានភារកិច្ច ៖

- រៀបចំកម្មវិធីសិក្សា និងការបណ្តុះបណ្តាល រួមទាំង សិក្ខាសាលាដទៃទៀត
- រៀបចំបង្កើត តាក់តែង និងកំណត់ឯកសារ សម្រាប់ការបណ្តុះបណ្តាលទាក់ទងនឹងវិស័យពាណិជ្ជកម្ម
- អនុវត្ត និងធ្វើបច្ចុប្បន្នភាព ការកសាងសមត្ថភាពប្រចាំឆ្នាំ របស់មន្ត្រីក្រសួងពាណិជ្ជកម្ម និងរៀបចំផែនការបណ្តុះបណ្តាល
- អភិវឌ្ឍន៍ឯកសារបណ្តុះបណ្តាល ដើម្បីឆ្លើយតបនឹងតម្រូវការទូទៅ និងតម្រូវការបណ្តុះបណ្តាលជាក់លាក់របស់ក្រសួងពាណិជ្ជកម្ម
- អភិវឌ្ឍន៍ និងរក្សាប្រព័ន្ធទិន្នន័យឯកសារបណ្តុះបណ្តាល និងទិន្នន័យរបស់អ្នក

បណ្តុះបណ្តាល ដែលមានស្រាប់

- រៀបចំសកម្មភាពសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក
- បង្កើតប្រព័ន្ធវាយតម្លៃ សម្រាប់មុនការបណ្តុះបណ្តាល និងក្រោយការបណ្តុះបណ្តាល ដើម្បីតាមដានការអភិវឌ្ឍន៍ របស់អ្នកដែលទទួលបានផលប្រយោជន៍ ពីវិទ្យាស្ថាន តាមរយៈព័ត៌មានត្រឡប់
- គាំទ្រការផ្សព្វផ្សាយគោលនយោបាយយុទ្ធសាស្ត្រ និងលទ្ធផលស្រាវជ្រាវ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៦** : ការិយាល័យអភិវឌ្ឍន៍ភាពជាដៃគូ និងអាជីវកម្ម មានភារកិច្ចៈ

- ស្វែងរកដៃគូ បង្កើត និងជំរុញការបណ្តុះបណ្តាល និងស្រាវជ្រាវ
- រៀបចំអនុស្សរណៈយោគយល់ អនុស្សរណៈកិច្ចព្រមព្រៀង លិខិតនៃកិច្ចព្រមព្រៀង ជាមួយដៃគូពាក់ព័ន្ធ ព្រមទាំងពិធីចុះហត្ថលេខាពាក់ព័ន្ធ
- សហការស្រាវជ្រាវ និងបណ្តុះបណ្តាល ដែលបង្កើតឡើងនៅក្នុងក្រសួងពាណិជ្ជកម្ម ដោយអង្គការពាណិជ្ជកម្មពិភពលោក អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសន្និសីទសហប្រជាជាតិ សម្រាប់ពាណិជ្ជកម្ម និងការអភិវឌ្ឍ។ល។
- ធ្វើការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និងរបកគំហើញថ្មី របស់ក្រសួងពាណិជ្ជកម្ម និងស្ថាប័នជាតិ និងអន្តរជាតិ
- ផ្តល់ប្រឹក្សាលើការធ្វើអាជីវកម្ម និងការធ្វើវិនិយោគ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៧** :

ការិយាល័យស្រាវជ្រាវ មានភារកិច្ច ៖

- រៀបចំការសិក្សាស្រាវជ្រាវ និងវិភាគទីផ្សារ នៃលំហូរផលិតផលកម្ពុជា និងការសិក្សាស្រាវជ្រាវពាក់ព័ន្ធដទៃទៀត
- អនុវត្ត និងធ្វើបច្ចុប្បន្នភាពផែនការស្រាវជ្រាវប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម
- អភិវឌ្ឍន៍ឯកសារសិក្សាស្រាវជ្រាវ ដើម្បីឆ្លើយតបនឹងតម្រូវការទូទៅ និងតម្រូវការស្រាវជ្រាវជាក់លាក់ របស់ក្រសួងពាណិជ្ជកម្ម និងសហគមន៍ខាងក្រៅ
- រៀបចំអាហារូបករណ៍សម្រាប់ការស្រាវជ្រាវ និងសម្ព័ន្ធភាព និងកិច្ចព្រមព្រៀងទៅវិញទៅមក ជាមួយស្ថាប័នបណ្តុះបណ្តាលជាតិ តំបន់ និងអន្តរជាតិ
- រៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវសម្រាប់មន្ត្រីក្រសួងពាណិជ្ជកម្ម
- អភិវឌ្ឍន៍ ថែរក្សា និងធ្វើបច្ចុប្បន្នភាពបណ្ណាល័យ របស់ក្រសួងពាណិជ្ជកម្ម រួមទាំងការ

ប្រើប្រាស់ទិន្នន័យស្រាវជ្រាវ

- ប្រមូល និងជូនដំណឹងអំពីការផ្តល់ឱកាសស្រាវជ្រាវ ដោយដៃគូអភិវឌ្ឍន៍ដល់មន្ត្រីក្រសួងពាណិជ្ជកម្ម និងសហគមន៍ខាងក្រៅ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៨** :

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពចំណុះក្រសួង និងមន្ទីរពាណិជ្ជកម្ម រាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

<u>**កន្លែងទទួល៖**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ

## អង្គការលេខ វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ

